00417287

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22/12/2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លេខ / No: D180/6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

Kingdom of Cambodia
Nation Religion King

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22/12/2009
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**លេខសំណុំរឿង: ០០២/១៩-០៩-២០០៧-អ.វ.ត.ក..-ក.ស.ច.ស.**

ចំពោះមុខ ៖ **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម Marcel LEMONDE (ម៉ាសែល ឡឺម៉ុង)**

កាលបរិច្ឆេទ៖ **ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩**

ភាសាដើម៖ **ខ្មែរ/អង់គ្លេស**

ចំណាត់ថ្នាក់ឯកសារ៖ **សាធារណៈ**

---

# ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹង ការបាត់ខ្លួនដោយបង្ខំ

---

**សហព្រះរាជអាជ្ញា**
អ្នកស្រី ជា លាង
លោក Andrew CAYLEY

**ជនត្រូវចោទ**
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន
កាំង ហ្កេកអ៊ាវ
ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
នី ច័ន្ទឌី ឡោ ជុនធី
គង់ ពិសី ហុង គីមសួន
យុង ផានិត គីម ម៉េងឃី
ម៉ុច សុវណ្ណារី ស៊ិន សុវ៉ន
ជេត វណ្ណលី ពេជ អង្គ
Silke STUDZINSKY
Phillipe CANONNE
Elizabeth Rabesandratana
Pierre-Olivier SUR
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud

**មេធាវីការពារក្តី**
សុន អរុណ Michiel PESTMAN
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅសៀង Diana ELLIS
ស សុវ៉ាន Jacques VERGES
ការ សាវុទ្ធ François ROUX
Marie-Paule CANIZARES

00417288



យើង **យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញការបន្តការស៊ើបសួរលើឈ្មោះ **នួន ជា** (NUON Chea) និង **ជនដទៃ** ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យលើ**បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ ដល់ មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦

បានឃើញវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. ("វិធានផ្ទៃក្នុង")

បានឃើញសំណើសុំបំពេញកិច្ចស៊ើបសួររបស់ក្រុមមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ធ្វើឡើងនៅថ្ងៃ ៣០ មិថុនា ២០០៩ (D180) ("សំណើសុំ")

បានឃើញចម្លើយតបរួមរបស់ក្រុមមេធាវីការពារក្តីចំពោះសំណើសុំបំពេញកិច្ចស៊ើបសួររបស់ភាគីដើម្បីបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ធ្វើឡើងដោយក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ និងក្រុមមេធាវីការពារក្តី នួន ជា ចុះថ្ងៃ ២៤ កក្កដា ២០០៩ (D180/2) ("ចម្លើយតបរួម")

បានឃើញចម្លើយតបរបស់ក្រុមមេធាវីការពារក្តី អៀង សារី ចំពោះសំណើសុំបំពេញកិច្ចស៊ើបសួររបស់ក្រុមមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ និង

សំណើសុំបន្ថែមចំនួនទំព័រ ធ្វើឡើងនៅថ្ងៃ ០៦ សីហា ២០០៩ (D180/4) ("ចម្លើយតបរបស់អៀង សារី)

បានឃើញដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបន្ថែមចំនួនទំព័រ ធ្វើឡើងនៅថ្ងៃ ០៨ កញ្ញា ២០០៩ (D180/5)

## សេចក្តីសំអាងរបស់ភាគី

១. នាថ្ងៃ ៣០ មិថុនា ២០០៩ សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសំណើសុំរួមមួយ ដែលក្នុងនោះ ពួកគេបានលើកឡើងថា មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីកំណត់ថា ការបាត់ខ្លួនដោយបង្ខំ គឺជាបទល្មើសនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[1] និងបានផ្តល់នូវបញ្ជីឈ្មោះបុគ្គលដែលបានធ្វើពាក្យបណ្តឹងអំពីការបាត់ខ្លួនដោយបង្ខំនេះ[2]។

២. ចម្លើយតបរួមនេះបានលើកឡើងថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនអាចនឹងធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងជាមួយនឹងអង្គហេតុ ដែលមិនមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមបាននោះទេ[3]។ ចម្លើយតបរួមបានបន្ថែមទៀតថា មិនមានមូលដ្ឋានណាមួយដើម្បីកំណត់ថា ការបាត់ខ្លួនដោយបង្ខំជាបទល្មើសនៅក្នុងច្បាប់ព្រហ្ម

---

[1] D180 ចំពោះសំណើសុំបំពេញកិច្ចស៊ើបសួររបស់ក្រុមមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ថ្ងៃ ៣០ មិថុនា ២០០៩ កថា. ២៦។

[2] D180 ចំពោះសំណើសុំបំពេញកិច្ចស៊ើបសួររបស់ក្រុមមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ថ្ងៃ ៣០ មិថុនា ២០០៩ កថា. ២៧។

[3] D180/2 ចម្លើយតបរួមរបស់ក្រុមមេធាវីការពារក្តីចំពោះសំណើសុំបំពេញកិច្ចស៊ើបសួររបស់ភាគីដើម្បីបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ថ្ងៃ ២៤ កក្កដា ២០០៩ កថា. ៥-៦។

ទណ្ឌអន្តរជាតិនោះទេ[4] ហើយសំណើសុំបែបនេះគួរត្រូវបានបដិសេធចោលក្នុងខ្លឹមសារទាំងស្រុង[5]។

៣. ចម្លើយតបរបស់ អៀង សារី បានស្នើឱ្យសហចៅក្រមស៊ើបអង្កេតបដិសេធមិនទទួលយកសំណើសុំនោះ ដោយហេតុថាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមិនបានប្តឹងដល់សហចៅក្រមស៊ើបអង្កេតអំពីអង្គហេតុនៃការបាត់ខ្លួនដោយបង្ខំនេះ[6] ដូច្នេះភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនអាចនឹងធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរ ដោយមិនមានដីកាបញ្ជូនរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទិននឹងបញ្ហានេះបានទេ[7]។ ម្យ៉ាងវិញទៀត មានការលើកឡើងថាសំណើសុំគួរតែត្រូវបានបដិសេធចោល ដោយហេតុថា វាមិនមានមូលដ្ឋានណាមួយ ដែលអាចកំណត់ថា ការបាត់ខ្លួនដោយបង្ខំជាបទល្មើសនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិនោះទេ[8]។

## **សំអាងហេតុនៃសេចក្តីសម្រេច**

៤. អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ភាគីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត *"ចេញដីកា ឬបំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ"*។ វិធាន ៥៥(១០) ផ្តល់ដល់ភាគី រួមបញ្ចូលទាំងភាគីដើមបណ្តឹងរដ្ឋប្បវេណីផង នូវឆន្ទានុ

---

[4] D180/2 ចម្លើយតបរួមរបស់ក្រុមមេធាវីការពារក្តីចំពោះសំណើសុំបំពេញកិច្ចស៊ើបសួររបស់ភាគីដើម្បីបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ថ្ងៃ ២៤ កក្កដា ២០០៩ កថា. ៤៤-៤៧។

[5] D180/2 ចម្លើយតបរួមរបស់ក្រុមមេធាវីការពារក្តីចំពោះសំណើសុំបំពេញកិច្ចស៊ើបសួររបស់ភាគីដើម្បីបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ថ្ងៃ ២៤ កក្កដា ២០០៩ កថា. ៤៤-៤៧។

[6] D180/4 ចម្លើយតបរបស់ក្រុមមេធាវីការពារក្តី អៀង សារី ចំពោះសំណើសុំបំពេញកិច្ច ស៊ើបសួររបស់ក្រុម មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ និងសំណើសុំបន្ថែមចំនួនទំព័រ ធ្វើឡើងនៅថ្ងៃ ០៦ សីហា ២០០៩ កថា. ១០។

[7] D180/4 ចម្លើយតបរបស់ក្រុមមេធាវីការពារក្តី អៀង សារី ចំពោះសំណើសុំបំពេញកិច្ច ស៊ើបសួររបស់ក្រុម មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ និងសំណើសុំបន្ថែមចំនួនទំព័រ ធ្វើឡើងនៅថ្ងៃ ០៦ សីហា ២០០៩ កថា. ១១។

[8] D180/4 ចម្លើយតបរបស់ក្រុមមេធាវីការពារក្តី អៀង សារី ចំពោះសំណើសុំបំពេញកិច្ច ស៊ើបសួររបស់ក្រុម មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ និងសំណើសុំបន្ថែមចំនួនទំព័រ ធ្វើឡើងនៅថ្ងៃ ០៦ សីហា ២០០៩ កថា. ១៣-៣៧។

00417291



សិទ្ធិក្នុងការកំណត់អំពីខ្លឹមសារនៃសំណើសុំនេះ ហើយដែលសហចៅក្រមស៊ើបអង្កេតក៏មានឆន្ទានុសិទ្ធិដូចគ្នាផងដែរក្នុងការសម្រេចអំពីទម្រង់នៃចម្លើយតប ដែលអាស្រ័យទៅតាមប្រភេទនៃសំណើសុំនោះ។ នៅក្នុងដីកាសម្រេចនេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា សំណើសុំមានលក្ខណៈច្បាស់លាស់ និងត្រឹមត្រូវ ដើម្បីជាជំនួយដល់ការស្វែងរកការពិត[9]។

៥. ផ្ទុយពីអ្វីដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តី អៀង សារី សហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមបានបង្ហាញអំពីអង្គហេតុជាច្រើនដែលទាក់ទងនឹងការបាត់ខ្លួនប្រជាជន។ ជាឧទាហរណ៍ មានការលើកឡើងអំពីការបាត់ខ្លួនប្រជាជននៅតាមការដ្ឋាន[10] ឬមន្ទីរសន្តិសុខ[11] ប្រជាជនដែល

---

[9] សូមមើល អ.វ.ត.ក. អ.ប.ជ.២៤ D164/4/13 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម SMD* ថ្ងៃ ១៨ វិច្ឆិកា ២០០៩ កថា. ៤៤-៤៦

[10] សូមមើលជាឧទាហរណ៍ D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ថ្ងៃ ២០ កក្កដា ២០០៧ កថា. ៤៧៖ *"ការចាប់ខ្លួនបានធ្វើជាបន្តបន្ទាប់ អ្នកណាធ្វើខុសត្រូវនាំខ្លួនទៅឆ្ងាយហើយសម្លាប់ចោល។ ប្រជាជានដែលបាត់ខ្លួនត្រូវបានជំនួសជាប្រចាំដោយអ្នកជាប់ឃុំថ្មី"*។ សូមមើលផងដែរ Schedule លេខ 48 ដែលមាននៅក្នុង D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២០ កក្កដា ២០០៧ កថា. ១៤។ Schedule លេខ 59 ដែលមាននៅក្នុង D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២០ កក្កដា ២០០៧ កថា. ៤៣។ D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២០ កក្កដា ២០០៧ កថា. ៤៤។ និង D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២០ កក្កដា ២០០៧ កថា. ៤៨។

[11] សូមមើលជាឧទាហរណ៍ D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២០ កក្កដា ២០០៧ កថា. ៦៤៖ *"នៅពេលយប់ អ្នកទោសឋានៈខ្ពស់ត្រូវបានដឹកតាមឡានធំៗឆ្ពោះទៅទិសខាងលិចទៅក្រចេះ។ អ្នកទាំងនេះបានបាត់ខ្លួនរហូត និងអាចត្រូវបានសម្លាប់"*។ សូមមើលផងដែរ D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២០ កក្កដា ២០០៧ កំណត់យោងចុងទំព័រលេខ ២៤៥។ D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២០ កក្កដា ២០០៧ កថា. ៦៣។ D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២០ កក្កដា ២០០៧ កថា. ៦៧។ D83 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងមន្ទីរសន្តិសុខភូមិភាគឧត្តរ ថ្ងៃ ២៦ មីនា ២០០៨ កថា. ៩។

បាត់ខ្លួនដោយសារមានរស់នៅក្នុងក្រុមគ្រួសារខ្មែរកាត់ វៀតណាម[12] ប្រជាជនចាមដែលបាត់ខ្លួន[13] និងអង្គហេតុទាក់ទងនឹងការបាត់ខ្លួនស្រដៀងគ្នាដទៃទៀត[14]។

៦. ទោះបីជា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ ក.ស.ព. មិនបានប្រើប្រាស់ឱ្យបានច្បាស់លាស់នូវពាក្យ "ការបាត់ខ្លួនដោយបង្ខំ" ក្នុងការកំណត់អំពីប្រភេទនៃបទល្មើសទៅតាមអង្គហេតុយ៉ាងណាក្តី[15] សហចៅក្រមស៊ើបអង្កេតធ្វើការរំលឹកថា សហចៅក្រមស៊ើបអង្កេតមិនមានកាតព្វកិច្ចក្នុងការកំណត់យកប្រភេទបទល្មើសដូចគ្នានឹងអ្វីដែលធ្វើឡើងដោយ ក.ស.ព. នោះទេ[16]។ សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងចំពោះអង្គ

---

[12] សូមមើល D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២០ កក្កដា ២០០៧ កថា. ៦៩៖ *"បានធ្វើនយោបាយសម្លាប់ប្រជាជនវៀតណាមទាំងអស់នៅក្នុងខេត្តព្រៃវែង។ ផ្នែកមួយនៃនយោបាយនេះតម្រូវថាពួកវៀតណាមមានឪពុកបានរៀបការជាមួយម្តាយជាខ្មែរត្រូវនាំខ្លួន និងសម្លាប់ ហើយតម្រូវផងដែរឱ្យដកចេញ ឬសម្លាប់ទាំងម្តាយទាំងកូន បើម្តាយជាវៀតណាម។ នយោបាយដូចគ្នានេះត្រូវបានអនុវត្តនៅខេត្តស្វាយរៀងដែរ"*។

[13] សូមមើលជាឧទាហរណ៍ D196 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអំពើប្រល័យពូជសាសន៍លើជនជាតិចាម ថ្ងៃ ៣១ កក្កដា ២០០៩ កថា. ១៤៖ *"នៅឃុំក្រូចឆ្មារ មានប្រជាជនចាមរាប់រយនាក់ត្រូវបានប្រមូលទុកនៅវត្តខ្សាច់ប្រឆេះ។ មនុស្សចាស់ និងកូនក្មេងត្រូវបានគេយកចេញទៅ ដោយទូក/កាណូត ហើយមិនដែលឃើញវិលត្រលប់វិញទេ"*។ សូមមើលផងដែរ D196 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអំពើ ប្រល័យពូជសាសន៍លើជនជាតិចាម ថ្ងៃ ៣១ កក្កដា ២០០៩ កថា. ១៧។ D196 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអំពើ ប្រល័យពូជសាសន៍លើជនជាតិចាម ថ្ងៃ ៣១ កក្កដា ២០០៩ កំណត់យោងចុងទំព័រលេខ ៨។ D196 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអំពើប្រល័យពូជសាសន៍លើជនជាតិចាម ថ្ងៃ ៣១ កក្កដា ២០០៩ កំណត់យោងចុងទំព័រលេខ ៤០។

[14] សូមមើលជាឧទាហរណ៍ D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២០ កក្កដា ២០០៧ កំណត់យោងចុង ទំព័រលេខ ៥២១។ D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ២០ កក្កដា ២០០៧ កំណត់យោងចុង ទំព័រលេខ ៥៤២។ Schedule លេខ 20។ Schedule លេខ 49។ Schedule លេខ 51។ Schedule លេខ 55។ Schedule លេខ ៦៥។ Schedule លេខ 71។ Schedule លេខ 72។ Schedule លេខ 75។ Schedule លេខ 78។ Schedule លេខ 89។ Schedule លេខ 100។

[15] វិធានផ្ទៃក្នុង(វិសោធនកម្មលើកទី ៤) ថ្ងៃ ១១ កញ្ញា ២០០៩ វិធាន ៥៣(១)(ខ) និងវិធាន ៥៣(១)(គ)៖ សហព្រះរាជអាជ្ញាត្រូវបានតម្រូវឱ្យធ្វើការកំណត់អំពីប្រភេទនៃបទល្មើស និងលើកឡើងអំពីបញ្ញត្តិច្បាប់ដែលកំណត់ និងផ្តន្ទាទោសលើបទឧក្រិដ្ឋនោះតែប៉ុណ្ណោះ។

[16] សូមមើល សំណុំរឿងលេខ ០០១ (អ.ប.ជ. ០២) D99/3/42 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃ ០៥ ធ្នូ ២០០៨ កថា. ៣៥-៣៩។ D198/1 ដីកាសម្រេចលើសំណើសុំបញ្ជាក់បំភ្លឺ ដាក់ដោយសហព្រះរាជអាជ្ញា ថ្ងៃ ២០ វិច្ឆិកា ២០០៩ កថា. ១០។

00417293



ហេតុដែលមានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ហើយសហចៅក្រមស៊ើបអង្កេតមានសិទ្ធិក្នុងការពិនិត្យសម្រេចលើការកំណត់ប្រភេទបទល្មើសចំពោះអង្គហេតុដែលត្រូវបានប្ដឹងនោះ[17]។

៧. បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេតរំលឹកថា សហចៅក្រមស៊ើបអង្កេតមិនតម្រូវឲ្យធ្វើការកំណត់ប្រភេតបទល្មើសឡើយ រហូតដល់ពេលចេញដីកាដំណោះស្រាយ[18]។ ដូច្នេះ នៅត្រឹមដំណាក់កាលនេះ វាមិនទាន់មានការចាំបាច់ដែលត្រូវធ្វើការវិភាគឲ្យបានពេញលេញលើធាតុផ្សំនៃបទល្មើសទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំនៅឡើយនោះទេ។ សហចៅក្រមស៊ើបអង្កេតនឹងពិនិត្យពិចារណាលើការលើកឡើងរបស់ភាគីនៅត្រង់ចំណុចនេះនៅក្នុងការតាក់តែងដីកាដំណោះស្រាយ។

៨. ទោះបីជាសហចៅក្រមស៊ើបអង្កេតមិនអាចបង្ហាញជាមុននូវខ្លឹមសារនៃដីកាដំណោះស្រាយតាមរយៈការបញ្ជាក់បំភ្លឺលើការកំណត់ប្រភេទបទល្មើសចំពោះអង្គហេតុដែលប្ដឹងមកក៏ដោយ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ចំពោះចំណុចដែលថា ការបាត់ខ្លួនដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្រោមមាត្រា ៧(១)(i) នៃលក្ខន្តិកៈក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចដែលមានបកស្រាយនៅក្នុងធាតុផ្សំនៃបទឧក្រិដ្ឋ (the Elements of Crimes)[19]។

---

17 សហចៅក្រមស៊ើបអង្កេតបានរកឃើញភស្តុតាង និងបានពណ៌នាអំពីអង្គហេតុទាក់ទងនឹងការធ្វើទារុណកម្មនៅព្រៃស (ស-២៤) នៅក្នុងដីកាដំណោះស្រាយ ទោះបីជាបទល្មើសទារុណកម្ម ដែលកើតមាននៅព្រៃសនេះមិនត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ។ សូមមើល D99 ដីកាដំណោះស្រាយ ករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃ ០៨ សីហា ២០០៨ កថា. ១០៦។ និង D3 ដីកាសន្និដ្ឋាន បញ្ជូនរឿងឲ្យស៊ើបសួរ ២០ កក្កដា ២០០៧ កថា. ៤៨ និង ១២២។

18 វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៤) ១១ កញ្ញា ២០០៩ វិធាន ៦៧(២)។

19 បន្ថែមលើនេះ មាត្រា ៩ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្ដីអំពីការកាត់ទោសនៅក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ បានចែងអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយយោងទៅលើលក្ខន្តិកៈក្រុងរ៉ូមឆ្នាំ ១៩៩៨ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។

00417294



៩. ដូច្នេះ សហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ការបាត់ខ្លួនដោយបង្ខំអាចនឹងត្រូវបានកំណត់ជាបទល្មើស នៅក្រោមការស៊ើបសួរនៅទីកន្លែង និងទីតាំងឧក្រិដ្ឋកម្ម ដែលមានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

១០. សហចៅក្រមស៊ើបអង្កេតរំលឹកអំពីឆន្ទានុសិទ្ធិរបស់ខ្លួន ដែលផ្តល់ដោយវិធាន ៥៥(១០) ក្នុងការឆ្លើយតបចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរ ដូចមានលើកឡើងក្នុងកថាខណ្ឌទី ៤ ខាងលើ។ ទាក់ទងជាមួយនឹងឈ្មោះបុគ្គលដែលត្រូវសម្ភាស ដែលមានលើកឡើងនៅក្នុងសំណើសុំ សហចៅក្រមស៊ើបអង្កេតកំពុងបន្តធ្វើការវាយតម្លៃលើភស្តុតាង ហើយនឹងរៀបចំឲ្យមានការសម្ភាសន៍បុគ្គលទាំងនោះ ទៅតាមករណីចាំបាច់ ឬចេញដីកាបន្ថែមមុនប្រកាសបិទការស៊ើបសួរ។

## អាស្រ័យហេតុនេះ

**សម្រេច** ទទួលយកសំណើដែលធ្វើឡើងដោយភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃ ៣០ មិថុនា ២០០៩។

**សម្រេច** តាមសំណើសុំឲ្យមានការបំពេញកិច្ចស៊ើបសួរទាក់ទងនឹងមនុស្សដែលបាត់ខ្លួននៅតាមទីកន្លែងឧក្រិដ្ឋកម្ម ដែលមានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

**កត់សម្គាល់** លើចំណុចដែលថា ការកំណត់បទល្មើសនឹងត្រូវធ្វើឡើងនៅក្នុងដីកាដំណោះស្រាយ បន្ទាប់ពីការវិភាគ និងវាយតម្លៃលើភស្តុតាង។

**កត់សម្គាល់** លើចំណុចដែលថា បញ្ជីឈ្មោះបុគ្គលដែលត្រូវសម្ភាសកំពុងត្រូវបានពិនិត្យ ហើយប្រសិនបើចាំបាច់ នឹងមានការចេញនូវដីកាបន្ថែមមុនពេលបិទការស៊ើបសួរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩

សហចៅក្រមស៊ើបអង្កេត

**Marcel LEMONDE**

យូ ប៊ុនឡេង